# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ សាត អឿន ភេទស្រី អាយុ៥០ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កងចល័ត

## ស្រុកកំណើតនៅភូមិក្រឡា ឃុំអូរជុំ ស្រុកអូរជុំ ខេត្តរតនគិរី

## រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០០:៥២:៣២

## ២៦ទំព័រ

ដានីៈ ជំរាបសួរ ខ្ញុំចង់ស្គាល់ឈ្មោះមីង មីងឈ្មោះអីដែរ?

អឿនៈ ខ្ញុំឈ្មោះអឿន ហ្នឹងហើយ ។

ដានីៈ ត្រកូលអីអឿន?

អឿនៈ សាត អឿន ។

ដានីៈ អាយុប៉ុន្មានហើយ?

អឿនៈ ខ្ញុំហាហើយ ។

ដានីៈ ហាប៉ុន្មានទៅ? កើតឆ្នាំសត្វអីទៅ? សត្វគោ សត្វជ្រូក ។

អឿនៈ អត់ដឹងសត្វអីដែរ ម៉ែខ្ញុំស្លាប់ ។

ដានីៈ ដាក់ក្នុងអត្តសញ្ញាណបណ្ណ ។

អឿនៈ អត្តសញ្ញាណបណ្ណខ្ញុំគេធ្វើណានោះ ។

ដានីៈ ដាក់ឆ្នាំមួយពាន់ប្រាំបួនរយប៉ុន្មានទៅ ។

អឿនៈ មួយពាន់ប្រាំបួនរយប៉ុន្មានទេ ៧៩រត់មករហូត ៧៩ខ្ញុំនៅក្មេងអាយុ១៥ទេ ។

ដានីៈ កាលឆ្នាំ៧៩អាយុ១៥ទេ?

អឿនៈ ចា៎! ខ្ញុំរត់មករហូត ។

ដានីៈ អីចឹងមីងថាអាយុ៥០ ។

អឿនៈ ចា៎!

ដានីៈ ស្រុកកំណើតមីងនៅណាទៅ? ភូមិអីទៅ?

អឿនៈ ភូមិក្រឡា ស្រុកអូរជុំ ។

ដានីៈ ឃុំអីហ្នឹង?

អឿនៈ ឃុំហ្នឹងហើយ ឃុំមែង ។

ដានី៖ ស្រុកអូរជុំ?

អឿន៖ ចា៎!

ដានី៖ ខេត្តអីហ្នឹង?

អឿន៖ ខេត្តរតនគិរី ។

ដានី៖ មីងជនជាតិអី?

អឿន៖ ជនជាតិគ្រឹង បងប្អូនខ្ញុំ៨នាក់នៅស្រុក ។

ដានី៖ ឪពុកឈ្មោះអីដែលមីង?

អឿន៖ ឪពុកឈ្មោះប្រាវ ។

ដានី៖ គាត់នៅរស់ ឬក៏ខូចហើយ?

អឿន៖ ពុកខ្ញុំ និងម៉ែខ្ញុំស្លាប់បាត់ហើយ តាំងពីសង្គ្រាមអាមេរិកទម្លាក់គ្រាប់បែក ។

ដានី៖ ស្លាប់កាលជំនាន់សង្គ្រាមអាមេរិកទម្លាក់គ្រាប់បែក?

អឿន៖ ចា៎!

ដានី៖ ស្លាប់ទាំងឪពុក ទាំងម្តាយ?

អឿន៖ ចា៎! ស្លាប់ទាំងអស់ ខ្ញុំនៅក្មេង នៅតូចៗ នៅជាមួយបងខ្ញុំ ។

ដានី៖ ម្តាយឈ្មោះអីទៅ?

អឿន៖ ឈ្មោះ ពើយ ។

ដានី៖ ម្តាយឈ្មោះ បើយ?

អឿន៖ ចា៎!

ដានី៖ ហើយបងប្អូនប៉ុន្មាននាក់ទៅ?

អឿន៖ បងប្អូន៨នាក់ ស្រីទាំងអស់ ។

ដានី៖ មីងកូនទីប៉ុន្មានទៅ?

អឿន៖ ខ្ញុំពៅគេ ពៅហើយព្រោះម៉ែខ្ញុំស្លាប់មានកូនណា៎ ។

ដានី៖ ហើយមីងសព្វថ្ងៃរស់នៅភូមិអី?

អឿន៖ ខ្ញុំនៅទួលប្រាសាទ ។

ដានី៖ សព្វថ្ងៃនៅភូមិទួលប្រាសាទ?

អឿន៖ ចា៎!

ដានី៖ ឃុំអីដែលហ្នឹង?

អឿន៖ ឃុំទំនប់ដាច់ ។

ដានី៖ ស្រុកអីមីង?

អឿន៖ ស្រុកត្រពាំងប្រាសាទ ។

ដានី៖ ខេត្ត?

អឿន៖ ខេត្តឧត្តរមានជ័យ ។

ដានី៖ មីងមានកូនចៅប៉ុន្មាននាក់ហើយសព្វថ្ងៃ?

អឿន៖ ខ្ញុំកូន២នាក់ ចៅនោះ១ ។

ដានី៖ ធំៗហើយកូន២នាក់?

អឿន៖ ចាំ! កូនខ្ញុំធំៗអស់ហើយ នេះមួយ នៅថៃមួយ ។

ដានី៖ ស្រីទាំងពីរ ឬប្រុស១ ស្រី១?

អឿន៖ ស្រីទាំង២ហ្នឹង ។

ដានី៖ គ្រួសារមីងឈ្មោះអីដែរ?

អឿន៖ គ្រួសារខ្ញុំមុនស្លាប់បាត់ហើយ នេះឈាង ។

ដានី៖ គ្រួសារមុនស្លាប់?

អឿន៖ ចាំ!

ដានី៖ គាត់ឈ្មោះអី?

អឿន៖ ប្ដីខ្ញុំមុន ។

ដានី៖ មីងថាម៉ិញឈ្មោះអីឈាង?

អឿន៖ ប្ដីខ្ញុំស្លាប់?

ដានី៖ បាទ!

អឿន៖ ឈ្មោះ ហុន នេះឈ្មោះឃាង ។

ដានី៖ គាត់ឈ្មោះអីឃាង ដែរ?

អឿន៖ អ៊ុំ សុខឃាង ។

ដានី៖ អីចឹងមីងកាលពីក្មេងៗមីងបានរៀនសូត្រដល់ថ្នាក់ណាដែរ?

អឿន៖ មិនបានរៀនទេ រៀនបានថ្នាក់ទី១-២ល្មមរត់ចូលព្រៃ យួនចូលស្រុក វៃគ្នា ។

ដានី៖ មីងចាំកាលជំនាន់កាលយើងបែកឆ្នាំ៧៥ ពេលដែលខាងខ្មែរក្រហមដឹកនាំប្រទេសហើយបាយរួមមីងចាំទេ?

អឿន៖ ចាំ ។

ដានី៖ កាលហ្នឹងមីងចូលធ្វើអី?

អឿនៈ កាលហ្នឹងគេប្រមូលបាយរួម ម៉ែឪខ្ញុំធ្វើចំការបានស្រូវច្រើនណាស់ ឡើងគេប្រមូលដាក់រួម ប្រមូលគោ ប្រមូលដាក់រួមទាំងអស់ គេមិនឲ្យយើងទេ គេប្រមូលស្រូវ ប្រមូលអង្ករទៅអស់រលីង ។

ដានីៈ គេប្រមូលដាក់រួមអីចឹង កាលហ្នឹងមីងធ្វើអីវិញទៅ? គេឲ្យធ្វើអី?

អឿនៈ គ្មានធ្វើអី គេឲ្យធ្វើស្រែ យប់ព្រលប់ កណ្ដាលយប់អាធ្រាត្រហើយគេឲ្យបបរប៉ុណ្ណេះព្រឹកល្ងាច ។ ព្រឹកបបរប៉ុណ្ណេះ យប់ប៉ុណ្ណេះ គេវាល់បាយ ។

ដានីៈ ហូបឆ្អែតអត់គេឲ្យប៉ុណ្ណឹង?

អឿនៈ អត់ឆ្អែតទេ ។

ដានីៈ ប៉ុណ្ណឹង ប៉ុណ្ណា?

អឿនៈ ចានប៉ុណ្ណឹងបបរ គេចែករាល់ថ្ងៃហ្នឹង ឆ្អែតមិនឆ្អែតខ្លះទៅលួចដំឡូងគេវ៉ៃចោល ។

ដានីៈ គេវ៉ៃចោលដែលកាលហ្នឹង?

អឿនៈ ចាស៎! ដល់ស៊ីមិនឆ្អែតខ្លះទៅលួចដំឡូង គេទាន់គេវ៉ៃចោលយើងងាប់ទៅ ។

ដានីៈ កាលហ្នឹងមីងនៅណា? កាលជំនាន់ប៉ុលពត?

អឿនៈ ខ្ញុំនៅបាធឡុង ទេ នៅវ៉ើនសៃ គេជម្លៀសតាមភូមិ តាមស្រុកអស់រលីង គេអត់ឲ្យនៅភូមិស្រុកទេ គេប្រមូលអង្ករ គេនៅចំរុះគ្នា នៅភូមិគេ ភូមិឯង ។

ដានីៈ ជម្លៀសអីចឹង ជម្លៀសពីស្រុកកំណើតទៅនៅវ៉ើនសៃវិញ?

អឿនៈ ចាស៎!

ដានីៈ ទាំងឪពុកម្ដាយ?

អឿនៈ ចាស៎!

ដានីៈ ទៅជាមួយគ្នា ទៅនៅជាមួយឪពុកម្ដាយឬយ៉ាងម៉េច?

អឿនៈ ខ្លះបងប្អូននៅនេះ ខ្លះនៅនេះ គេចែកគ្នានៅ មិនដឹងម៉េចអត់ដឹងដែរ ។ អង្ករស្រូវមិនដឹងអ្នកណាប្រមូលអស់រលីង អត់មានអីស៊ីទេ ។

ដានីៈ អត់មានអីហូបទេ?

អឿនៈ ចាស៎!

ដានីៈ អីចឹងគេជម្លៀសឲ្យមកនៅវ៉ើនសៃ?

អឿនៈ ចាស៎!

ដានីៈ ទាំងអស់គ្នាអ្នកនៅស្រុកកំណើតមីង នៅខាងភូមិកាឡា ភូមិមៃ មកទាំងអស់?

អឿនៈ ចាស៎!

ដានី៖ មកនៅវ៉ើនសៃទាំងអស់?

អឿន៖ ខ្លះនៅកន្លែងស្រែពក មួយភូមិហ្នឹងគេចែកគ្នានៅ មិនដឹងយ៉ាងម៉េច ដល់គេយកអង្គរ យកស្រូវអស់។

ដានី៖ ដល់ពេលមកនៅវ៉ើនសៃគេឲ្យហូបតែបបរមួយចានៗ?

អឿន៖ ចា៎! ហូបបបរមួយចានៗ នៅភូមិគេ ដល់យើងមានស្រូវ មានអង្គរណា ហូបតែបបរមួយចានៗ។

ដានី៖ គេឲ្យធ្វើការងារអីខ្លះទៅកាលហ្នឹង?

អឿន៖ គេធ្វើស្រែធម្មតាដែរ ធ្វើស្រែរួម គេឲ្យហូបតិចៗ។

ដានី៖ តែមីងនៅជាមួយបងប្អូនឪពុកម្ដាយ ឬក៏បែក? គេអត់ឲ្យនៅជាមួយគ្នា?

អឿន៖ គេទុកខ្ញុំនៅនោះ។

ដានី៖ នៅណា?

អឿន៖ នៅត្រពាំងព្រេះ នៅជិតស្រែពក បានខ្ញុំរត់មករហូត។

ដានី៖ នៅត្រពាំងព្រេះ ធ្វើអីទៅ?

អឿន៖ នៅនោះគេឲ្យធ្វើស្រែដែរ គេឲ្យធ្វើស្រែភូមិគេ ធ្វើស្រែប្រមូលដាក់រួមគេមិនឲ្យស៊ីទេ។

ដានី៖ កាលហ្នឹងប្រធានគេឈ្មោះអី?

អឿន៖ ប្រធានហ្នឹងស្លាប់អស់ហើយ ប្រធានសហករណ៍យើង គេវ៉ៃចោលកាលរត់យួន គេវ៉ៃចោលអស់ហើយ។

ដានី៖ គេវ៉ៃចោល?

អឿន៖ ចា៎!

ដានី៖ ពីណាវ៉ៃចោល?

អឿន៖ មិនដឹងពីណា អត់ដឹងដែរ យប់គេអូសទៅៗ ខ្ញុំឆ្ងល់ គេមិនហ៊ានជួយទៀត ស្រែកអូយៗជួយ ខ្សែអង្រឹងអូសគ្នាទៅ។

ដានី៖ មីងនៅក្នុងស្រុកអីគេទៅ?

អឿន៖ នៅស្រុកនៅត្រពាំងព្រេះ នៅអូរឆ្វាំង។

ដានី៖ អូរឆ្វាំងហ្នឹងស្រុកអីគេ?

អឿន៖ ខ្ញុំទៅនៅភូមិគេ។

ដានី៖ ដូចមីងនៅរតនគិរីមីងនៅអូរជុំ ទៅដល់នោះស្រុកអីទៅវិញ?

អឿន៖ ខេត្តជាមួយគេហើយ។

ដានី៖ ខេត្តជាមួយ ខេត្តរតនគិរី បើនៅវឺនសៃ ស្រុកវឺនសៃ ចុះនៅអូរព្រេះស្រុកអី?

អឿន៖ អូរព្រេះនោះដែរ ស្រុកអូរជុំដែរ គេជម្លៀស ។

ដានី៖ កាលហ្នឹងមេធំជាងគេឈ្មោះអីទៅ នៅខាងរតនគិរី?

អឿន៖ មេធំឈ្មោះ តាខាត់ គេវ៉ៃចោលដែរ ។

ដានី៖ តាខាត់ គេវ៉ៃចោលដែរ?

អឿន៖ ចា៎! តាខាត់ ខ្ពស់ស្រឡះ ឡើងស ដូចបារាំងអីចឹង ។

ដានី៖ តាខាត់ ជនជាតិយើងដែរ ឬជនជាតិខ្មែរ?

អឿន៖ មិនដឹងជនជាតិអី តែស ខ្មែរដែរបានគេវ៉ៃចោល ។

ដានី៖ ដែលជួបតាខាត់ ដែរ?

អឿន៖ ជួប ។

ដានី៖ ហើយមីងមកធ្វើស្រែនៅអូរព្រេះបានយូរទេ?

អឿន៖ នៅមួយឆ្នាំ ដល់នៅធ្វើមួយឆ្នាំហើយ រត់មកស្រុកយើងវិញ គេជម្លៀសរហូត ។

ដានី៖ មួយឆ្នាំ អីចឹងមកស្រុកយើងវិញ?

អឿន៖ ចា៎!

ដានី៖ មកធ្វើអីនៅស្រុក?

អឿន៖ មកស្រុកយើងគេប្រមូលៗយួនទៅស្រុករត់មកចូលព្រៃ ។

ដានី៖ តែមកដល់ស្រុកកំណើតអត់ទាន់បានធ្វើអីទេ?

អឿន៖ អត់បានធ្វើអីទេ ។

ដានី៖ អត់បានធ្វើស្រែ ។

អឿន៖ អត់បានទេ ។

ដានី៖ មីងថាធ្លាប់ទៅធ្វើរោងចក្រ?

អឿន៖ ខ្ញុំមកពីត្រពាំងព្រេះឯងខ្ញុំទៅធ្វើរោងចក្រ ។

ដានី៖ មកពីត្រពាំងព្រេះមកធ្វើរោងចក្រនៅណា?

អឿន៖ នៅកន្លែងអរចេង នៅលំផាត់ ។

ដានី៖ ហ្នឹងគេជ្រើសរើសមីងពីធ្វើស្រែនៅអូរព្រេះ មកនៅរោងចក្រ?

អឿន៖ ចា៎!

ដានី៖ រោងចក្រហ្នឹងរោងចក្រអីគេ?

អឿន៖ រោងចក្រក្រមា មុង ភួយ ដល់ហ្នឹងបាន២-៣ឆ្នាំរត់តែម្តង ។

ដានីៈ មានត្រឡប់មកស្រុកកំណើតវិញដែរ?

អឿនៈ អត់ត្រឡប់ទេ ។

ដានីៈ កាលហ្នឹងរោងចក្រហ្នឹងនៅធ្វើក្រមា ធ្វើមុង ភួយ នៅកន្លែងអីគេអូរចេង?

អឿនៈ ចាំ! អូរចេង ។

ដានីៈ អូរចេងហ្នឹងនៅម្តុំណាទៅ?

អឿនៈ គណៈតំបន់នៅនេះ ផ្លូវជាតិអីលេខ១៩ ។

ដានីៈ ស្រុកអីគេហ្នឹង?

អឿនៈ ស្រុកលំផាត់ហ្នឹង ។

ដានីៈ កាលហ្នឹងប្រធានរោងចក្រគេឈ្មោះអី?

អឿនៈ ឈ្មោះតាសុវណ្ណ ។ តាសុវណ្ណ ក៏ងាប់ដែលមិនឃើញទេ ងាប់កាលវត់យួននោះ ងាប់អស់ហើយ ។

ដានីៈ ហើយមេធំៗជាងគេតាណា?

អឿនៈ តាខាត់ហ្នឹងឯងធំជាងគេ ។ តាខាត់ គេវ៉ៃចោលអស់ហើយ ។

ដានីៈ ដល់ពេលធ្វើរោងចក្របានរយៈពេលប៉ុន្មានទៅ?

អឿនៈ ខ្ញុំធ្វើបាន៣ឆ្នាំគេវត់យួន គេវ៉ៃគ្នា ។

ដានីៈ ដល់ពេលមកដល់រោងចក្រហូបចុកគ្រប់គ្រាន់ដែរ?

អឿនៈ ហ្នឹងក៏ហូបបបរដដែលហ្នឹង យប់ព្រលប់ធ្វើការងើបតាំងពីម៉ោង៤ ធ្វើការរហូត ទៅណាក៏ហូបបបរដែរ ប្រជាជនក៏ហូបបបរដែរ មិនដឹងគេប្រមូលអង្ករ ស្រូវទៅណា ស្រូវទាំងគោនៗ ប្រជាជនខំធ្វើមិនបានហូបផង ។

ដានីៈ តែមកដល់រោងចក្រហូបបបរ ហូបប៉ុន្មានពេលមួយថ្ងៃ?

អឿនៈ ព្រឹក-ល្ងាចប៉ុណ្ណឹង ។

ដានីៈ តែ២ពេលទេ?

អឿនៈ ចាំ! ដល់ថ្ងៃឡើងពីណាគេឃ្លានទៅជីកដំឡូង ទៅកាប់ចេក ។

ដានីៈ គេឲ្យដែរ?

អឿនៈ គេឃើញគេវ៉ៃចោល គេមិនមែនវ៉ៃទទេណាំ អីចឹងៗគេវ៉ៃចោល ។

ដានីៈ ជំនាន់ហ្នឹងមីងធ្លាប់ឃើញគេវ៉ៃចោលដែរ?

អឿនៈ ខ្ញុំឃើញគេវ៉ៃចោល ខ្ញុំឃើញគេអូសបងថ្លៃខ្ញុំឈ្មោះ តើ ប្រែម ប្រធានឃុំ គេអូសទៅវ៉ៃចោល ។

ដានី៖ ប្រធានឃុំអី?

អឿន៖ ឃុំនៅអូរដុំហ្នឹងគេវៃចោល ។

ដានី៖ ឃុំឈ្មោះអី?

អឿន៖ ឃុំមែង ។

ដានី៖ ឃុំមែង ស្រុកអូរដុំហ្នឹង?

អឿន៖ ចា៎!

ដានី៖ គាត់ត្រូវជាបងថ្លៃរបស់មីង?

អឿន៖ ចា៎!

ដានី៖ គាត់ឈ្មោះអី?

អឿន៖ ឈ្មោះបងប្រែន ។

ដានី៖ បងប្រែន ហ្នឹងគេអូសយកទៅវៃចោល?

អឿន៖ ចា៎!

ដានី៖ ឃើញផ្ទាល់ភ្នែកអត់?

អឿន៖ យប់ ព្រឹកឡើងគេយកអង្រឹងមកឲ្យ គេសែងទៅ ។

ដានី៖ ពីណាអ្នកសែងទៅ?

អឿន៖ អត់ដឹង យប់ គេមិនឲ្យយើងឃើញទេថ្ងៃ ។

ដានី៖ ហើយគេយកអង្រឹងមកឲ្យយើងវិញ ។

អឿន៖ ចា៎! ប្រពន្ធមិនហ៊ានយំ តែហ៊ានយំគេវៃចោលទាំងប្រពន្ធ ។

ដានី៖ ម៉េចដឹងថាប្រពន្ធយំ គេវៃចោលទាំងប្រពន្ធ?

អឿន៖ មិនហ៊ានយំទេ វាគំរាមយើង អ្នកយកអង្រឹងមកឲ្យយើង គំរាមៗវៃចោលតែម្តង ។

ដានី៖ វៃចោលឆ្នាំណា?

អឿន៖ ៧៩ហ្នឹង ។

ដានី៖ មីងឃើញគេអូសផ្ទាល់ភ្នែកអត់?

អឿន៖ លឺយប់ គេយកយប់មិនមែនថ្ងៃ យប់គេអូស ។

ដានី៖ លឺថាម៉េច?

អឿន៖ លឺថាអូយៗ គេអូសទៅ គេបង្ខំយកទៅ គេបង្ខំទៅ ។

ដានី៖ មីងជឿថាមានគេសម្លាប់ដែលកាលជំនាន់ហ្នឹង?

អឿនៈ គេសម្លាប់អស់ប៉ុន្មាននាក់ប្រធានសហករណ៍របស់ពួកខ្ញុំ ឃុំពួកខ្ញុំគេសម្លាប់អស់ហើយ ។ សម្ភាសន៍មិនដឹងយកខ្ញុំទៅ ។

ដានីៈ អត់អីទេមីង ដូចខ្ញុំជំរាបមីង ខ្ញុំជាអ្នកប្រវត្តិសាស្ត្រប្រមែលប្រមូលចង់ក្រងជាឯកសារ ។ អីចឹងមីងពេលដែលគេយកបងថ្លៃទៅគេច្រើនតែយកពេលយប់ទេ?

អឿនៈ ចាំ! គេយកទៅវៃចោល ។

ដានីៈ ពេលថ្ងៃអត់យកទៅទេ?

អឿនៈ អត់ ។

ដានីៈ យកទៅវៃចោលហ្នឹងយកតែពេលយប់ទេ?

អឿនៈ យកតែពេលយប់ ខ្លះកំពុងតែសរសេរៗសៀវភៅពីរនាក់កូន យប់ឡើងគេហៅចុះ ចុះមកទៅជួបខ្ញុំតិច ទៅជួបណា គេយកទៅ ព្រឹកឡើងបាត់ មិនដឹងយកទៅណា គេវៃចោល ។

ដានីៈ គេយកទៅវៃចោល?

អឿនៈ ចាំ! បាត់រហូត ។

ដានីៈ មីងកាលនៅរោងចក្រ អ្នកនៅក្នុងរោងចក្រមានគេយកទៅវៃចោលដែលអត់?

អឿនៈ ខ្ញុំអត់ឃើញទេ ។ គេមិនឲ្យយើងដឹងទេ មេៗមិនដឹងបាត់ទៅណាគេវៃចោល ។

ដានីៈ គេអត់ឲ្យយើងដឹងទេ?

អឿនៈ ចាំ! មិនដឹងទេ គេយកយប់ទៅ ។

ដានីៈ មីងធ្វើរោងចក្រហ្នឹងរហូតដល់បែកយួនចូលឆ្នាំ៧៩?

អឿនៈ ចាំ!

ដានីៈ ដល់ពេលយួនចូលយ៉ាងម៉េចទៀតទៅ មីងរៀបរាប់?

អឿនៈ មានអី ខ្ញុំរត់រហូតក្នុងព្រៃ ដឹកដំឡូង ដឹកក្តួច អត់មានបាយទេ ។

ដានីៈ មីងអត់ទៅផ្ទះវិញទេ? អត់ទៅជួបបងប្អូន?

អឿនៈ អត់ទេ មិនហ៊ានទៅផ្ទះទេគេគំរាមយើង ។

ដានីៈ ពីណាគំរាម?

អឿនៈ យើងមិនហ៊ានទៅផ្ទះ តែហ៊ានទៅគេវៃចោលយើង ។

ដានីៈ ពីណាថា?

អឿនៈ ពួកនៅជាមួយគ្នា អ្នករត់ជាមួយគ្នា ប្រុសៗ ។

ដានីៈ ប្រុសៗខាងខ្មែរក្រហម?

អឿនៈ ចាំ!

ដានីៈ គំរាមយើងទៀត?

អឿនៈ ចា៎!

ដានីៈ គំរាមថាម៉េច?

អឿនៈ គេមិនគំរាមទេ តែយើងទៅ ផុតកន្លែងយើងបន្តិចគេទៅតាមបាញ់សាប់ ប្ដីប្រពន្ធវានាំគ្នាទៅស្រុក ដែលកំពុងដេកតាមផ្លូវគេទៅតាមបាញ់គ្នាតាមផ្លូវ បាញ់នឹងអង្រឹងសាប់ពីរនាក់ប្ដីប្រពន្ធ ។

ដានីៈ ម៉េចបានទៅតាមបាញ់គ្រាន់តែគេអត់ទៅជាមួយ?

អឿនៈ គេខ្លាចឃើញកន្លែងគេនៅ គេរាយការណ៍ឲ្យយួនមកវ៉ៃយើង ។

ដានីៈ គេខ្លាចបែកការណ៍?

អឿនៈ ហ្នឹងហើយ ។

ដានីៈ យើងធ្លាប់នៅជាមួយគេ ដល់យើងចេញពីគេមក?

អឿនៈ ហ្នឹងហើយ ខ្លាចយើងទៅរាយការណ៍ឲ្យគេកន្លែងនៅ កន្លែងនេះៗ គេតាមសម្លាប់យើង ។

ដានីៈ អីចឹងមីងយួនចូលតាមគេរហូត?

អឿនៈ ចា៎!

ដានីៈ តាមគេទៅនៅកន្លែងណាខ្លះទៅ?

អឿនៈ នៅតាមជើងភ្នំ នៅក្នុងព្រៃ ធ្វើដំឡូង ធ្វើក្ដួចហូបរហូត អត់មានអំបិល អត់មានប៊ីចេងហូបទេ ។

ដានីៈ ពេលដែលយើងនៅរតនគិរី ពេលដែលយើងរត់តាមគេ រត់ដល់ណាទៅ?

អឿនៈ រត់មកហ្នឹង មកមេគង្គ ឆ្លងមេគង្គមកនេះ ខ្លះជិះទូក ខ្លះជិះក្បូនទៅ ខ្លះហែល ខ្លះសាប់តាមទឹកហ្នឹង ។

ដានីៈ តែដំបូងយើងអត់ទាន់ឆ្លងទន្លេមេគង្គ កាលហ្នឹងយើងនៅក្នុងព្រៃ នៅរតនគិរីហ្នឹង?

អឿនៈ ចា៎! នៅហ្នឹងរតនគិរី នៅភ្នំអត់ហ៊ានចូលស្រុកទេ លឺដែលឆ្កែព្រួសអត់ហ៊ានទេ លឺគេថាយួនៗមកតាមសម្លាប់យើង គេថាយួនតាមសម្លាប់យើង ព្រោះយួនដេញវ៉ៃខ្មែរក្រហមមែន វាសែងឆ្នាំងធំៗដេញវ៉ៃពួកខ្ញុំ ដេញបាញ់ពួកខ្ញុំ ។

ដានីៈ នៅយូរអត់នៅក្នុងព្រៃខាងរតនគិរី?

អឿនៈ ២០ឆ្នាំ ទំរាំពួកខ្ញុំមកនេះបានសុខសាន្ត គេតាមវ៉ៃរហូត ។

ដានីៈ យើងនៅក្នុងព្រៃហ្នឹងយូរអត់? ដែលយើងឆ្លងទន្លេមេគង្គមក ជិះក្បូន?

អឿនៈ យួរដែរ ធ្វើស្បៀង ធ្វើក្តូច ហាលកិនធ្វើស្បៀងបានឆ្លង ដឹកដំឡូងទៀនហូប ស្ងោរទៅ បេះតែរស់ទៅ ។

ដានីៈ ដល់ពេលយើងឆ្លងទន្លេមេគង្គមក ជិះទូក ជិះក្បូន ឆ្លងកន្លែងណាមក?

អឿនៈ ឆ្លងកន្លែងដីលាវ មុំពានោះ ។

ដានីៈ តែយើងឆ្លងរតនគិរីដំបូង គេហៅកន្លែងហ្នឹងកន្លែងអីកាលយើងជិះក្បូនមក?

អឿនៈ ណា ។

ដានីៈ កន្លែងយើងឆ្លងទន្លេមេគង្គមក ឆ្លងពីត្រើយខាងកើត មកខាងលិច?

អឿនៈ ពួកខ្ញុំទៅធ្វើដំឡូងកន្លែងអូរត្រពាំងគល់ ។

ដានីៈ នៅណា?

អឿនៈ នៅអូរត្រពាំងគល់ ។

ដានីៈ ខេត្តអីគេហ្នឹង?

អឿនៈ ខេត្តស្ទឹងត្រែង ។

ដានីៈ ដល់យើងឆ្លងមកចំណា?

អឿនៈ មិនចំភូមិទេ រត់តាមព្រៃរហូត កាត់ព្រៃអត់ដើរតាមផ្លូវទេ ខ្លាចគេឃើញ គេវៃ ។

ដានីៈ ដល់ពេលរត់កាត់យើងឆ្លងពីនោះមក យើងកាត់ព្រៃរហូតបានមកដល់ ។

អឿនៈ តាមព្រៃរហូត ។

ដានីៈ ចុះមឹងមានប្រសាសន៍ថាតាមដីលាវ?

អឿនៈ នោះដីលាវ ។

ដានីៈ នៅណា?

អឿនៈ ឆ្លងមកដីលាវ មកដល់នេះមុំពា ដើរកាត់ដីលាវហ្នឹង ដើរកាត់តាមភូមិពេលយប់ ។

ដានីៈ ឆ្លងកាត់មកដល់មុំពា យើងឡើងដល់លើមុំតែម្តង?

អឿនៈ ដល់មុំពា ដល់ទន្លេងល្ពៅពួកអង្គការគេ តាប៉ុល ពត គេប្រមូលអង្ករ ទិញអង្ករឲ្យពួកខ្ញុំហូប មកដល់នេះលែងហូបដំឡូង ហូបក្តូចហើយ ទៅដល់ភ្នំដងរែក ខ្ញុំមកពីរតនគិរីឆ្លងព្រៃរហូត មកដល់កន្លែងតាប៉ុល ពត គេប្រមូលកំលាំងទិញអង្ករឲ្យហូប បើកអីចិនៗ គេបើកជំនួយ ក្រណាត់ សារ៉ុង នៅក្នុងព្រៃមានអីស្លៀក ខោអាវមួយចង្កេះហ្នឹង ។

ដានីៈ យ៉ាំងម៉េចទៀតទៅយើងមកដល់មុំពាហើយ?

អឿនៈ មកដល់នេះ មកនៅរហូតសព្វថ្ងៃនេះ នៅៗទាល់តែវៃគ្នា ពួកខ្ញុំបែកគ្នា ។

ដានីៈ មឹងពេលមកដល់មុំពាធ្វើអីទៀត? យើងធ្វើប្រជាជន ឬធ្វើកងទ័ព?

អឿនៈ ពួកខ្ញុំធ្វើប្រជាជន ស្រីៗមានធ្វើអីកើត មានធ្វើអីៗ

ដានីៈ មីងនៅក្នុងអង្គភាពកងណាទៅពេលមកដល់មុំ?

អឿនៈ ខ្ញុំនៅប្រជាជនម្តងហើយ ធ្វើប្រជាជនម្តង កាលហ្នឹងពួកអង្គការកាកបាទគេជួយ ពួកកាកបាទគេជួយប្រមូលប្រជាជនៗនៅជាមួយគ្នា កាកបាទគេជួយៗ

ដានីៈ នៅមុំពបានប៉ុន្មានឆ្នាំទៅ?

អឿនៈ ពួកខ្ញុំមុំពបានមួយឆ្នាំដើរតាមផ្លូវ មិនដឹងប៉ុន្មានឆ្នាំមកដល់នេះ ដើរដេកៗអត់ម្ហូបដឹកជំឡូងសិនទៅ ធ្វើក្លូចៗ

ដានីៈ កាលហ្នឹងប្រធានមីងពីណាគេ មកដល់មុំព?

អឿនៈ តាធី កងវរៈៗ

ដានីៈ ហើយកងពលណា?

អឿនៈ ៨៣ គេថា៨៣ៗ

ដានីៈ ពីគេធ្វើមេធំ?

អឿនៈ តាធី និងតាប្រៗ តាប្រ ស្លាប់បាត់ហើយ តាធី រត់ទៅណាស្លាប់ដែរ ស្លាប់អស់រលីងៗ

ដានីៈ តាប្រ គាត់ស្លាប់ដែរ?

អឿនៈ ចាំ!

ដានីៈ តាប្រ គាត់ធ្វើអី?

អឿនៈ តាប្រ គាត់ធ្វើប្រធានកងពលៗ

ដានីៈ កងពលលេខប៉ុន្មាន?

អឿនៈ លេខប៉ុន្មានទេៗ

ដានីៈ ពេលដែលនៅមុំពមិនមែននៅជាមួយតាសារឿន ទេ?

អឿនៈ ពួកខ្ញុំ?

ដានីៈ បាទ! មីងមិនមែននៅជាមួយតាសារឿន តា០៥ទេ?

អឿនៈ ហ្នឹងហើយមកដល់មុំព មកនៅទន្លេល្ពៅ មកនៅជាមួយតា០៥រហូតផ្តើមទិញអង្ករជួយប្រជាជន ខ្វះស្រីៗគេឲ្យលីគ្រាប់ដឹកជញ្ជូន វៃគ្នាៗ

ដានីៈ មីងមានធ្វើ ជួយបិទចំរូង?

អឿនៈ បិទចំរូងដាក់តាមក្រោយផ្ទះយើងហ្នឹង ឥឡូវគេមកវៃយើង ចាក់តាមផ្លូវៗ

ដានីៈ ចាក់ដីរ?

អឿនៈ ចាក់ដីរៗ

ដានី៖ ដីរឆក់?

អឿន៖ មិនមែនដីរឆក់ អត់មានទេ ដាក់ចំរូង អ្នកឆ្នៃគេដាក់ដីរឆក់ទៅ ។

ដានី៖ មីងចេះធ្វើដីរឆក់អត់?

អឿន៖ អត់ អត់ចេះ ខ្ញុំតាមគេដែលហ្នឹង បានតែកាប់ឫស្សីដាក់ធ្វើចំរូង ។

ដានី៖ ទៅនៅមុំពាហ្នឹងយ៉ាងម៉េចលែងលំបាកហើយអីចឹង?

អឿន៖ ទៅនៅមុំពា មកនេះលែងលំបាកហើយ គេឈប់វ៉ៃកន្លែង ដល់គេវ៉ៃកន្លែងរត់ទៀត ។

ដានី៖ តែនៅកន្លែងមុំពាយើងឈប់ហូបក្លូច យើងហូបបាយ ។

អឿន៖ លែងហូបក្លូចហើយ ហូបបាយ ពួកទ័ពគេឲ្យបាយ ឲ្យអង្ករ ឲ្យត្រីខ មី គេជួយមួយចប់ ពួកចិនគេជួយ ខោអាវស្បៀកពាក់ ។

ដានី៖ នៅមុំពាបានរយៈពេលប៉ុន្មានបានយួនដេញវិញ?

អឿន៖ ប្រហែល២០ឆ្នាំ ។

ដានី៖ នៅបានយូរម្ល៉េះ២០ឆ្នាំ?

អឿន៖ យូរដែលណាស់ ដាំចេក ដាំអំពៅទ្រុបទ្រុល តែ៣ឆ្នាំ ។

ដានី៖ ប៉ុន្មានឆ្នាំ?

អឿន៖ ៣ឆ្នាំ ។ ២០ឆ្នាំណាយើង៧៩ ច្រលំមាត់ ។

ដានី៖ នៅ៣ឆ្នាំហើយទៅណាទៀត?

អឿន៖ ខ្ញុំនៅ៣ឆ្នាំគេវ៉ៃគ្នាទៀត ទៅនៅនោះ នៅក-៧នៅថៃម្តង ។

អ្នកជិតខាង៖ គេវ៉ៃឆ្នាំប៉ុន្មាន?

អឿន៖ គេវ៉ៃ៨៤ គេវ៉ៃ១០០១ ។

ដានី៖ ១០០១វ៉ៃ៨៤?

អឿន៖ ចា៎!

ដានី៖ វ៉ៃ៨៤យើងរត់ទៅណា?

អឿន៖ រត់ទៅថៃ រត់នៅជាមួយថៃ ប្រទេសថៃ ។

ដានី៖ ដល់ពេលចេញពីប្រទេសថៃយើងមកនៅកន្លែងណាវិញ?

អឿន៖ មកនៅដីខ្មែរ ។

ដានី៖ អត់ទេ មុនដំបូងយើងចេញពី១០០៣យើងរត់ចូលទៅថៃ ហើយគេដឹកមកនៅត្រង់ណា?

អឿន៖ គេដឹកវៀងៗ គេកាត់ៗទៅនៅណានោះ នៅក-៧ ពេទ្យអូម ។

ដានី៖ ក-៧នៅម្តុំណាទៅ?

អ្នកជិតខាងៈ ក-៧ នៅទល់មុខនេះ ។

អឿនៈ នៅជាមួយដីថៃ ។

ដានីៈ មុំ១ហ្នឹងគេហៅអីគេ? នៅដីថៃគេហៅឈ្មោះអីខ្លះទីកន្លែង?

អ្នកជិតខាងៈ ឥឡូវមិនដឹងគេដាក់អីផង យើងមុនខ្មែរក្រហមមុនហៅក-៧ ។

ដានីៈ ក-៧ តែមុំហ្នឹងវាមានកន្លែងអីស៊ីងចាន់ ។

អឿនៈ ស៊ីងចាន់ហ្នឹងហើយ ថៃក៏មានដែលទំនប់វា ។

ដានីៈ ទំនប់ស៊ីងចាន់?

អឿនៈ ចា៎!

ដានីៈ ស៊ីងចាន់ ដងទង់ មុំហ្នឹង?

អឿនៈ ចា៎! គាត់ដឹងដែរ?

ដានីៈ ខ្ញុំដឹងខ្លះ១ តែចង់ដឹងក្រែងលោមីងដឹងច្រើនជាងហ្នឹងទៀត ។

អឿនៈ ហ្នឹងហើយ ។

ដានីៈ គេហៅអីទៀតមុំ១ហ្នឹង?

អឿនៈ ហៅកន្លែងចងក, ដងទង់ កន្លែងអូរគ្រាវដែលពួកបារាំងចាំបើកអន្តរឲ្យប្រជាជន កន្លែងរដ្ឋ គេចិញ្ចឹមរួម២-៣ឆ្នាំ គេបញ្ជូនមកនោះ មកដីខ្មែរអស់ ។

ដានីៈ ឆ្នាំប៉ុន្មានគេបញ្ជូនមកដីខ្មែរ?

អឿនៈ មិនដឹងប៉ែតប៉ុន្មានពូធា គេបញ្ជូនមកដីខ្មែរ ។

អ្នកជិតខាងៈ យើងចុះមកនៅឆ្នាំ៩០-៩១ ។ ចុះឆ្នាំ៩០ចុះមកយើងអន្លង់វែង ។

ដានីៈ អីចឹងឆ្នាំ៩០-៩១បានចុះមកអន្លង់វែង?

អឿនៈ ចា៎!

ដានីៈ មីងតាំងពីនៅមុំ៣ រហូតមកនៅក-៧ យើងនៅក្នុងកងពលដដែល ឬមានផ្លាស់ប្ដូរអីម៉េច ដែរ?

អឿនៈ នៅដដែល អត់ផ្លាស់ ។

ដានីៈ នៅជាមួយតាសារឿន(០៥)ដដែល?

អឿនៈ ចា៎!

ដានីៈ មីងនៅជាកងទ័ព ឬនៅជា?

អឿនៈ ខ្ញុំប្រជាជន ។

ដានីៈ ចុះមកដំបូងមកនៅណា?

អឿនៈ នៅអន្លង់វែង ។

ដានីៈ នៅម្តុំណា?

អឿនៈ នៅម្តុំអូរជីក ម្តុំផ្ទះតាម៉ុក ។

ដានីៈ នៅម្តុំផ្ទះតាម៉ុកទេដំបូង?

អឿនៈ ចាំ! កន្លែងអូរជីកទឹកលិច ។

ដានីៈ នៅហ្នឹងយូរទេ?

អឿនៈ យូរ នៅ៤-៥ឆ្នាំបានមកនេះ ។

ដានីៈ នៅហ្នឹងអត់មានទៅណាទៀត ចេញពីហ្នឹងមកនេះតែម្តង?

អឿនៈ មកនេះ ចេះតែផ្លាស់រហូត ។

ដានីៈ អត់មានរត់ទៅណា ឡើងភ្នំ?

អឿនៈ អត់មានឡើងភ្នំទេ មករហូត ។

អ្នកជិតខាងៈ អត់ម៉េច ឡើងមួយសារទៀត ។

អឿនៈ អ៎! កាលគេទម្លាក់គ្រាប់ ម្នាក់វៀចមាត់ផាប់ម្នាក់ហ្នឹង រត់ឡើងជប់រុន ។

ដានីៈ ឡើងជប់រុន?

អឿនៈ ចាំ! នៅរត់ឡើងទាហានថៃ ទៅនៅជាមួយទាហានថៃ កន្លែងជប់រុន កន្លែងព្រំដែន គេមក
ទម្លាក់គ្រាប់យន្តហោះ ។

ដានីៈ ហើយអីចឹងរត់ច្រើនដែរ រត់ទៅដល់ជប់រុន?

អឿនៈ ចាំ! រត់ទៅដល់ជប់រុន ។

ដានីៈ ទៅនៅយូរអត់?

អឿនៈ នៅយូរដែរ ២-៣ខែ ។

ដានីៈ ទៅនៅ២-៣ខែ ហើយមកណាទៀត?

អឿនៈ មកវិញ មកនេះវិញ ។ មកនេះវិញរត់ទៅអូរស្វាយ គេដុតផ្ទះរលីងពួកទាហានខ្មែរ ។

ដានីៈ ដល់ពេលដំបូង មកនៅដំបូងនៅណា?

អឿនៈ ពួកខ្ញុំ?

ដានីៈ នៅម្តុំហ្នឹង ឬនៅណា?

អឿនៈ នៅផ្ទះហ្នឹង ។

ដានីៈ នៅកន្លែងហ្នឹងតែម្តង?

អឿនៈ នៅកន្លែងតាអ៊ិន នៅភូមិនោះក្បែរទួលប្រាសាទ ។

ដានី៖ ភូមិណា?

អឿន៖ នោះ ។

ដានី៖ នៅកន្លែងភូមិគេនោះ?

អឿន៖ ចាំ!

ដានី៖ ដល់ពេលនៅហ្នឹងបានរយៈពេលប៉ុន្មានបានរត់ទៅអូរស្វាយទៀត?

អឿន៖ នៅហ្នឹងគេដុតផ្ទះរលីង មិនសល់សរសរផង ។

ដានី៖ និយាយមកនៅខាងទួលប្រាសាទប៉ុន្មានវេរៈទៅមកនៅទួលប្រាសាទ?

អ្នកជិតខាង៖ នៅហ្នឹងតែ មានតែកូនចៅតាពីន ។

ដានី៖ តាពីន វរសេនាធំ?

អ្នកជិតខាង៖ តាពីន វរសេនាធំ ។

ដានី៖ ចុះអនុតាពីន ពីណាគេ?

អ្នកជិតខាង៖ តាជឹម ខ្ញុំអត់នៅផងអត់ដឹងដែរ ។

ដានី៖ ចុះមីងពេលយើងរត់ទៅនៅអូរស្វាយយូរដែរ បានត្រឡប់មកវិញមួយសារទៀត?

អឿន៖ ទៅយូរដែរ ដល់ពេលតាម៉ុក ។

ដានី៖ អត់ដឹងឆ្នាំណាទេ?

អឿន៖ ខ្ញុំរត់អូរស្វាយកាលហ្នឹង ។

ដានី៖ កៅប៉ុន្មានទៅ? យើងចុះមកឆ្នាំ៩០ នៅទំនប់ដាច់បានរយៈពេលប៉ុន្មានបានរត់ទៅខាងជប់រុន?

អឿន៖ ៥ឆ្នាំដឹង បានរត់ចុះមកអូរស្វាយ ។

អ្នកជិតខាង៖ មានទៅបាន៥ណាំ រត់ចុះមក៩០-៩១-៩២ វៃគ្នាប្រឫកប្រឫល គ្នាឯងហ្នឹងទៀត

អឿន៖ វៃគ្នាអ្នកធំដូចគ្នា វៃគ្នាប្រឡូកគ្នា ។

អ្នកជិតខាង៖ វៃខ្មែរក្រហមដូចគ្នា ពួកតាម៉ុក ពួក០៥ ។

អឿន៖ តា០៥, តាប៉ុល ពត ងាប់នៅនោះ ។ តាម៉ុក រត់ទៅនោះ ពួកខ្ញុំរត់មកនេះ មកស្រអែមផ្តាច់ខ្លួន ។

ដានី៖ មីងដឹងរឿងគេឈ្លោះគ្នា? គេវៃគ្នា? ធំៗគេវៃគ្នា?

អឿន៖ ថាមេៗក្បត់ ។

ដានី៖ គេថាមេៗក្បត់?

អឿន៖ ចាំ!

ដានី៖ គេថាមេៗណាក្បត់?

អឿន៖ មិនដឹងមេណាក្បត់ ០៥ដឹងគេថាក្បត់ ។

ដានី៖ គេថាតា០៥ក្បត់?

អ្នកជិតខាង៖ ពួកនេះថាម្ចាស់ម្នាក់ ។

អឿន៖ ០៥គេចាប់ដាក់គុកហើយ តាម៉ុក ចាប់ដាក់គុកឆាប់បាត់ហើយ គេវ៉ៃចោលទាំងប្តី ទាំងប្រពន្ធបាត់ហើយ តាម៉ុក ក៏ស្លាប់បាត់ដែលឥឡូវ ។

ដានី៖ ពីណាក្បត់ពីណា បើតាមមីងដឹង?

អឿន៖ មិនដឹងពួកហ្នឹង សុទ្ធតែមេៗគេ ។

ដានី៖ បាទ?

អឿន៖ តាម៉ុក វ៉ៃចោលពួកនេះអស់ ។

ដានី៖ ពួកណា?

អឿន៖ ពួកតាពីន, ពួកនេះតាលាង ខ្លាចតាម៉ុកដាក់គុកដូចតា០៥ វ៉ៃចោល គាត់រត់ផ្តាច់ខ្លួនមកដីខ្មែរ នៅជាមួយពួកខេមរភូមិន្ទ ។ ដល់តាម៉ុកទៅ ពួកប៉ុល ពតរត់ទៅភ្នំបែកគ្នាជាពីរ ហ្នឹងហើយបែកបាក់គ្នា ។

ដានី៖ ចុះមីងរត់ទៅខាងណា?

អឿន៖ ខ្ញុំរត់មកនេះ ។

ដានី៖ រត់មកណា?

អឿន៖ តាមគេ រត់មកខាងខេមរភូមិន្ទ ។

ដានី៖ រត់មកខាងខេមរភូមិន្ទ?

អឿន៖ ចា៎!

ដានី៖ ជាមួយតាលាង, តាពីន ហ្នឹងទៅ?

អឿន៖ ហ្នឹងហើយ ពួកតាលាង, តាពីន ។

ដានី៖ តា០៥ គេវ៉ៃចោលបាត់ហើយ?

អឿន៖ ចា៎! តា០៥ គេវ៉ៃចោលបាត់ ។

ដានី៖ តាម៉ុក រត់ឡើងលើភ្នំ?

អឿន៖ ចា៎! តាម៉ុក រត់ឡើងភ្នំ ពួកខ្ញុំខ្លាចតាម៉ុកហ្នឹងចាប់ពួកខ្ញុំរត់ឡើងភ្នំទៀត ស្តាយអីៗមកនេះអស់រលីង មកនេះទាំងយប់ ខ្លាចតាម៉ុក ឃាត់ពួកខ្ញុំ ។ តាម៉ុក ទាន់ឃាត់ពួកខ្ញុំរត់ឡើងភ្នំ

ជាមួយគាត់ហើយ បើពួកខ្ញុំអត់រត់មកនេះផ្តាច់ខ្លួន ពួកខ្ញុំច្បាស់ជារត់ឡើងភ្នំ កៀងទៅរកភ្នំទៀតហើយ ។

ដានី: ខ្លាចតាម៉ុក កៀងយកទៅឡើងភ្នំជាមួយ?

អឿនៈ ចា៎! ហ្នឹងហើយ ពួកខ្ញុំរត់មកនេះអស់ទាំងយប់ ។

ដានី: យកទៅច្រើនអត់?

អឿនៈ ច្រើនពួកនោះមិនដឹងប៉ុន្មានកងពល បែកគ្នាពាក់កណ្តាល ។

ដានី: មីងជនជាតិគ្រឹងដូចមីងដែរ កាលហ្នឹងនៅជិតៗមីងច្រើនដែរ?

អឿនៈ មិនដឹងទៅណាទៅណីទេ ខ្លះនៅត្រពាំងប្រាសាទ ខ្លះនៅអូរស្មាច ។

ដានី: អត់ទេ កាលរត់មកពីរតនគិរីមកជាមួយគ្នា ច្រើនអត់?

អឿនៈ អត់មានទេ តែខ្ញុំម្នាក់ឯងហ្នឹង បែកបាក់ ។

ដានី: បែកបាក់បងប្អូន អត់មានបងប្អូនមកជាមួយទេ?

អឿនៈ អត់ទេ ខ្ញុំនៅជាមួយគេ ចេះនៅដែរ ដូចបងប្អូនបង្កើត ។

ដានី: មីងកាលពីក្មេងៗចេះនិយាយខ្មែរច្បាស់ដែរ?

អឿនៈ ខ្ញុំនិយាយអីចឹង ។

ដានី: និយាយច្បាស់អីចឹង?

អឿនៈ ចា៎!

ដានី: ពេលមកនៅម៉ុំព ទន្លេល្ពៅ នៅតែជាមួយខ្មែរ អត់មានជនជាតិមីងនៅជាមួយទេ?

អឿនៈ មានខ្លះ ខ្លះទៅណា ទៅណី ខ្លះទៅកោះកុង ខ្លះទៅម៉ាឡៃ ទៅតាមប្តីគេអីចឹង គេទៅអស់ ។

ដានី: ពេលដែលគេផ្លាស់មកទំនប់ដាច់ ក៏អត់មានជនជាតិ?

អឿនៈ អត់មានទេ មានតែខ្ញុំមួយ ។

ដានី: ចុះនៅខាង១០៥ ជនជាតិច្រើន មីងអត់ទៅនៅជាមួយទេ?

អឿនៈ ពួកនោះជនជាតិខុសគ្នា ពួកនោះព្នង ពួក១០៥ ។

ដានី: ១០៥ច្រើនព្នង ពួកមណ្ឌលគិរី?

អឿនៈ ចា៎! ពួកមណ្ឌលគិរី ខ្ញុំរតនគិរី ។

ដានី: ពេលមីងចូលទៅខាងខេមរភូមិន្ទ ទៅខាងណាខាងស្រែអែម?

អឿនៈ ចា៎! ខាងស្រែអែម ។

ដានី: ដល់ពេលផ្តាច់ខ្លួនហើយយ៉ាងម៉េចទៀតទៅ?

អឿនៈ ដល់ផ្តាច់ខ្លួនហើយធម្មតាដូចរាល់ថ្ងៃ ធ្វើស្រែ ធ្វើចំការ បានហូបបានចុកទៅគេលែងជួយអីហើយ ។

ដានីៈ គេលែងជួយ?

អឿនៈ ចា៎! ថតនេះ ។

ដានីៈ ដល់ពេលត្រឡប់ពីស្រែអែមមកនៅណាវិញ?

អឿនៈ នៅហ្នឹង ។

ដានីៈ មកនៅហ្នឹងវិញ មីងធ្លាប់ទៅលេងស្រុកកំណើតទេ?

អឿនៈ ទៅលេងនោះ រតនគិរី ។

ដានីៈ ជិះតាមណា?

អឿនៈ តាមសៀមរាប ចុះសៀមរាបទៅកំពង់ធំ កំពង់ចាម ហើយនៅក្រចេះ ហើយណាស្ទួងបានដល់ស្រុកខ្ញុំ ។

ដានីៈ ជិះទៅប៉ុន្មានថ្ងៃ?

អឿនៈ ជិះទៅមួយថ្ងៃដល់ ខ្ញុំអស់៦០ម៉ឺន ។

ដានីៈ អស់ប៉ុន្មាន?

អឿនៈ ៦០ម៉ឺន ពីនេះ ។

ដានីៈ ទៅប៉ុន្មាននាក់?

អឿនៈ ទៅពីរនាក់ ។

ដានីៈ ពីរនាក់ពីណា?

អឿនៈ ពីរនាក់នោះ ។

ដានីៈ ពីរនាក់ពូ?

អឿនៈ ចា៎!

ដានីៈ អស់៦០ម៉ឺនទាំងពីរនាក់?

អឿនៈ ចា៎! ទាំងទៅទាំងមក

ដានីៈ ទៅលេងប៉ុន្មានដងហើយ?

អឿនៈ ទៅម្តង ។

ដានីៈ ទៅឆ្នាំណា?

អឿនៈ ទៅប៉ុន្មាន ប៉ែតប៉ុន្មានទេ ឆ្នាំប៉ុន្មានទេ ខ្ញុំទៅលេង ។

ដានីៈ ទៅប៉ុន្មានឆ្នាំហើយ?

អឿនៈ ទៅ៣ឆ្នាំ ។

ដានីៈ មីងទៅដល់ស្រុកហើយ មីងអត់ចង់នៅហ្នឹង?

អឿនៈ អត់ចេះនៅទេ នឹកឃើញស្រែចំការ នៅនឹងមានស្រែ ចំការ ទៅហ្នឹងគេយកស្រែ ចំការ អស់រលីង អត់មានទេ ។

ដានីៈ អត់មានទេនៅរតនគិរី?

អឿនៈ អត់មានទេ ។

ដានីៈ តែយើងនៅនេះ យើងដាច់ពីបងប្អូនយើង?

អឿនៈ ចាំ!

ដានីៈ បងប្អូនយើងនៅនោះ យើងមានព្រះសែនយើង?

អឿនៈ តែបងប្អូនខ្ញុំថាឲ្យទៅនៅហ្នឹងទៅគេជួយមួយឆ្នាំ គេមិនមើលនឹងភ្នែកទេ ខ្ញុំអត់នៅ ដីស្រែនៅនេះបានច្រើនដែរ ។

ដានីៈ មីងនៅនេះមានដីស្រែច្រើនដែរ?

អឿនៈ ចាំ!

ដានីៈ អត់ចង់ទៅនៅនោះវិញ?

អឿនៈ អត់ចង់ទៅនោះ ។

ដានីៈ ទៅដល់នោះបងប្អូនប្រាប់ថា គេចង់ឲ្យមីងទៅនៅនោះដែរ?

អឿនៈ ចាំ! ឲ្យខ្ញុំទៅនៅហ្នឹងគេជួយមួយឆ្នាំ បងប្អូនខ្ញុំធ្វើតែស្រែចន្ទីហ្នឹង មួយឆ្នាំបានគេបេះធូរធាររបស់គេ មានតែខ្ញុំយ៉ាប់ក្រ ។

ដានីៈ នៅនោះគេធ្វើស្វាយចន្ទី?

អឿនៈ ចាំ!

ដានីៈ នៅខាងរតនគិរី?

អឿនៈ ចាំ!

ដានីៈ គេធូរធារ?

អឿនៈ គេធូរធារ ។

ដានីៈ គេធូរធារគេជួយមីង ម៉េចបានមីងអត់ចង់ទៅនៅ?

អឿនៈ ខ្ញុំអត់ទៅ ខ្ញុំធ្លាប់នៅនេះហើយ ខ្ញុំអត់នៅអត់កើត ។

ដានីៈ ធ្លាប់នៅនេះហើយ ទៅនៅនោះអត់កើត?

អឿនៈ ចាំ! នៅអត់កើត ។

ដានី: មីងកាលពីក្មេងៗអត់បានរៀនអក្សរទេ?

អឿន: អត់បានរៀនផង រៀនថ្នាក់ទី១-២លួមគេប្រមូលឲ្យធ្វើការងារ ធ្វើស្រែ ។

ដានី:ចេះអក្សរ អានអក្សរដាច់អត់?

អឿន: អត់ទេ ។

ដានី: អក្សរបទចំរៀងចេះអត់?

អឿន: អត់ ទទេសោះ ។

ដានី: ហើយមីងធ្លាប់និយាយរឿងរ៉ាវពីជីវិត ធ្លាប់រត់លូនកាត់ក្នុងព្រៃ គស៊ូបាញ់គ្នាប្រាប់កូនចៅដែលអត់ទេ?

អឿន: ប្រាប់កូនខ្ញុំទាំងអស់ កូនអើយស្រួលទេពួកឯងឥឡូវហ្នឹង បើខ្ញុំពិបាកណាស់ រត់ព្រៃ កាត់វាល ដឹកដំឡូង ដឹកក្ដួច គ្មានអំបិល គ្មានប្រហុកស៊ីដូចឥឡូវទេ ឥឡូវមានផ្សា ខោអាវក៏គ្មានស្លៀកដែរ បានមួយចង្កេះហ្នឹង ។

ដានី: កូនៗជឿអត់ពេលនិយាយប្រាប់?

អឿន: ជឿ ។

ដានី: កូនជឿដែរ?

អឿន: ចា៎!

ដានី: មីងធ្លាប់ឆ្លងកាត់ពីសម័យសង្គ្រាមតាំងពីក្មេងៗមក រហូតដល់យើងផ្ដាច់ខ្លួនហើយខុសគ្នាយ៉ាងម៉េចទៅ? ទាំងការរស់នៅ ជីវភាព សេរីភាព ខុសគ្នាម៉េចដែរបើតាមមីងយល់ដឹង?

អឿន: ខុសគ្នា មុនយ៉ាប់ណាស់ ឥឡូវវាស្រួល ។

ដានី: មុនយ៉ាប់យ៉ាងម៉េច?

អឿន: មុនលំបាកណាស់រត់យួន រត់លូន លំបាក ឥឡូវហ្នឹងក្រមានអីយើងធ្វើស្រែ ធ្វើចំការធម្មតាស្រួល ។ មុនរត់គ្រាប់ប្រដាក់ប្រដឹង រត់គេដេញគ្រាប់ គេបាញ់ គេដង្វាងគ្រាប់ប៉ឹងៗពីក្រោមនៅរស់ទៀតខ្ញុំ ។

ដានី: លំបាក ដល់ឥឡូវយ៉ាងម៉េច? តាំងពីផ្ដាច់ខ្លួនមក?

អឿន: ក្មួយឯងនៅណា?

ដានី: ខ្ញុំនៅភ្នំពេញ ។ មីងតាំងពីផ្ដាច់ខ្លួនហើយយ៉ាងម៉េចទៅ?

អឿន: ខ្ញុំនៅស្រួលធម្មតារកស៊ី ។

ដានី៖ មីងមកដល់សព្វថ្ងៃដូចយើងប្រតិបត្តិតាមប្រពៃណី ទំនៀមទំលាប់ពីជនជាតិមីងដែលអត់ទេ?

អឿន៖ ទេ បើថានៅជាមួយខ្មែរបានដូចគេហ្នឹង តាមគេ ។

ដានី៖ តាមពីណាគេ?

អឿន៖ តាមខ្មែរ ខ្មែរធ្វើម៉េចធ្វើអីចឹងដែរ ប្រពៃណីខ្មែរតាមខ្មែរ នៅជាមួយគេអីចឹងប្រពៃណីតាមគេអីចឹង ។

ដានី៖ ប្រពៃណីខ្មែរមីងធ្វើអីខ្លះ?

អឿន៖ ខ្ញុំធ្វើស្រែ ចំការ ទៅវត្ត ។

ដានី៖ មីងទៅវត្តដែរ?

អឿន៖ ចាំ!

ដានី៖ មីងទៅវត្តណា?

អឿន៖ នេះ វត្តនេះ ។

ដានី៖ វត្តអីគេវត្តហ្នឹង?

អឿន៖ វត្តទំនប់ដាច់ ។

ដានី៖ មីងទៅវត្តពេលណា?

អឿន៖ ព្រឹក ល្ងាច ភ្ជុំបិណ្ឌ ចូលឆ្នាំ ។

ដានី៖ ហេតុអីបានមីងទៅវត្តដែរ?

អឿន៖ ចាំ?

ដានី៖ ទៅវត្តធ្វើអី?

អឿន៖ ធ្វើវត្តធ្វើអី ទៅស្តាប់លោកទេសនា ។

ដានី៖ មីងសំពះលោក ស្តាប់លោកទេសនាហើយមានអារម្មណ៍ម៉េច?

អឿន៖ ខ្ញុំអត់អារម្មណ៍អី ចេះតែស្តាប់ធម្មតា មិនដូចមុនទេ យើងនៅក្នុងព្រៃយើងអត់ដឹងអី ។

ដានី៖ កាលពីរស់នៅក្នុងព្រៃយើងអត់ដឹងអីទេ?

អឿន៖ ចាំ! យើងអត់ដឹងអីទេ ឥឡូវទើបតែដឹងលោកខ្លះៗ ។

ដានី៖ ពីប្រពៃណីរបស់មីងគេធ្វើអីខ្លះកាលពីក្មេងៗ?

អឿន៖ ប្រពៃណីខ្ញុំអត់ទាន់ទេ ចាស់ៗខ្ញុំអត់ទាន់ផង ។

ដានី៖ តែមីងចាំទេគេធ្វើអីខ្លះ?

អឿន៖ អត់មានធ្វើអីទេ ។

ដានី៖ ដូចថាមានបុណ្យអីខ្លះទៅជនជាតិមីង?

អឿន៖ អត់ឃើញមានបុណ្យទេជនជាតិ។

ដានី៖ គេធ្វើអី?

អឿន៖ អត់ធ្វើអី។

ដានី៖ គេមានសែនព្រេន?

អឿន៖ គេសែនព្រេនជនជាតិពួកខ្ញុំ គេកាប់ចំការគេសែន គេស៊ីជីក គេសែនសុំលោកតាកាប់ព្រៃ ពេលច្រូតកាត់សែនមួយសារទៀតទៅ គេយកមាន់មួយ ស្រាមួយពាងទៅ។

ដានី៖ ដល់ពេលគេកាប់ចំការគេសែន គេច្រូតកាត់គេសែន តែពីរហ្នឹងទេ?

អឿន៖ ចា៎! ប៉ុណ្ណឹងឯង។

ដានី៖ គេសែនច្រើនតែមាន់ទេ?

អឿន៖ ចា៎! ជ្រូក។

ដានី៖ មាន់ ជ្រូក ហើយនិងស្រា?

អឿន៖ ចា៎!

ដានី៖ អត់មានក្របីទេ?

អឿន៖ ក្របីមានណា ក្របី គោ។

ដានី៖ ស្រាពាងយើងបានមកពីណា?

អឿន៖ គេបិទខ្លួនគេ ផ្លែឈើរបស់គេ។

ដានី៖ មីងចេះបិទទេ?

អឿន៖ អត់ចេះ ទាល់តែមានមេ។

ដានី៖ តែមីងមកធ្វើចំការនៅនេះ អត់មានសែនពេលកាប់ចំការ?

អឿន៖ អត់ អត់ធ្វើដូចគេទេ។

ដានី៖ នៅស្រុកនោះគេសែនដើម្បីអី?

អឿន៖ គេសែនអារក្សអ្នកតា ចាស់ៗពីដើមគេយកជំនឿរឿងចាស់ៗអារក្ស អ្នកតា គេបន់អាស្រម ឈឺគ្រុនគេមិនរកពេទ្យទេ គេរកអារក្សអ្នកតាច្រើនតែងាប់លឿន។

ដានី៖ ងាប់ច្រើន?

អឿន៖ ងាប់ច្រើន។

ដានី៖ អីចឹងទៅពេទ្យគ្រាន់បើជាង?

អឿនៈ ទៅពេទ្យគ្រាន់បើដាង គេគ្រាន់តែបន់អារក្ស អ្នកតា ខ្លះកាប់ជ្រូក ខ្លះកាប់មាន់អស់របស់ឯង ខ្លះកាប់គោអារក្សគេ ដូចគ្រូថាកាប់គោបានបាត់ កាប់គោងាប់ទៀត កាប់គោមួយទៅ កាប់ជ្រូកមួយទៅ ខ្មោចងាប់ទៀត ។ នៅអីចឹងខ្ញុំអត់បេះនៅទេ ខ្ញុំធ្លាប់នៅនេះហើយ ខ្ញុំខ្លាច ។

ដានីៈ អត់បេះនៅតាមគេវិញ?

អឿនៈ អត់បេះតាមទេ ខ្លាច ។

ដានីៈ តែមីងអត់ជឿទេ អារក្ស អ្នកតា អត់ជឿទេ?

អឿនៈ អត់ជឿទេ ខ្ញុំថាខ្មោចយើងងាប់គេទៅកប់អត់មានអីទេ គេសែន គេដុតសប្បាយ អត់ធ្វើបុណ្យដូចយើងទេ ខ្ញុំខ្លាចៗ ខ្មោចធ្វើអត់មានលោក ។

ដានីៈ នៅស្រុកមីងគេអត់មានលោកទេ?

អឿនៈ អត់មានលោកទេ ។

ដានីៈ អីចឹងមីងខ្លាចវិញ?

អឿនៈ ខ្ញុំខ្លាច ។

ដានីៈ ខ្លាចម៉េច?

អឿនៈ ខ្លាចខ្មោចធ្វើ អត់មានលោក អត់មានអាចារ្យបង្ក្រាប ។

ដានីៈ មីងខ្លាចខ្មោចលងអត់?

អឿនៈ ខ្លាច ។

ដានីៈ ឥឡូវហ្នឹងខ្លាចខ្មោចដែរ?

អឿនៈ ខ្លាច ខ្មោចគេកប់គេដាក់សង្កសី ប៉ុណ្ណេះទៅផុះនោះ ខ្មោចនៅនោះច្រើនណាស់ងាប់ ស្រុកនេះចាញ់ផង ចាញ់ទឹក ចាញ់ដី ។

ដានីៈ កូនមីងស្គាល់បងប្អូនអស់នៅខាងរតនគិរី?

អឿនៈ អត់ទាន់យកកូនខ្ញុំទៅផង ។

ដានីៈ បងប្អូនជីដូនមួយអត់ស្គាល់គ្នា?

អឿនៈ អត់ អត់បានយកទៅ ចាំថ្ងៃក្រោយមានលុយទៅលេងម្តង ហើយនាំកូនទៅលេងម្តង ខ្ញុំខ្ជិលជិះឡានទៅ ។

ដានីៈ ឥឡូវមីងមានចំការ ស្រែច្រើនដែលអត់?

អឿនៈ ស្រែខ្ញុំមួយហាត់កន្ទះក្រោយផ្ទះ ។

ដានីៈ ចំការ?

អឿនៈ ចំការបានមួយហាត់ដែរ ។

ដានីៈ ស្រែមួយហាត់កន្លះ ចំការបានមួយហាត់?

អឿនៈ ចា៎! ខ្ញុំអត់មានឧបករណ៍ធ្វើ ដីគគោកមុនខ្ញុំខ្ជិលចាប់ដីធ្វើតែប៉ុណ្ណឹងឯង ខ្ញុំអត់មានរបរ ។

ដានីៈ បានហូបចុកគ្រប់គ្រាន់ដែរ?

អឿនៈ ខ្ញុំ?

ដានីៈ បាទ!

អឿនៈ ធ្វើខ្វះ១-២ខែទិញគេហូបទៅ ។ បើថាធ្វើមួយហូបអត់ខ្វះទេ តែយើងចង់បានលុយលក់ទិញនេះទិញនោះហូបម្ហូប ។

ដានីៈ គ្រាន់តែហូបអត់ខ្វះទេ?

អឿនៈ ចា៎!

ដានីៈ ចុះបើដំឡូងយើងធ្វើបានច្រើនទេ?

អឿនៈ ដំឡូងធ្វើបាន១ហាត់ដែរហ្នឹងឆ្នាំនេះ ធ្វើ២ឆ្នាំ ។

ដានីៈ បានដកអស់នៅ?

អឿនៈ នៅមិនទាន់ដក ទើបតែកាប់ដើមទុក ។

ដានីៈ ទុកឆ្នាំក្រោយទៀត?

អឿនៈ ចា៎!

ដានីៈ មីងដល់បែកយួរអីចឹងអត់នឹកបងប្អូននៅរតនគិរីទេ?

អឿនៈ អត់នឹកទេ ធម្មតា អត់នឹកអីទេ ។

ដានីៈ ឥឡូវខស្សព្វាហ៍ទាក់ទងគ្នាអីដែលអត់?

អឿនៈ ទូរស័ព្ទឃើញទៅមកៗដែរ គេទៅគេមក ។

ដានីៈ គេទៅគេមក?

អឿនៈ គេគេមកខ្ញុំគេទៅដែរ ។

ដានីៈ មីងនៅនិយាយភាសាជនជាតិបានធម្មតា?

អឿនៈ អត់ ខ្ញុំអត់ដឹងផង ខ្ញុំអត់ចេះនិយាយទេ បើថាស្តាប់បាន តែនិយាយអត់កើតទេ ។

ដានីៈ ចុះនិយាយជាមួយបងប្អូននិយាយអី?

អឿនៈ និយាយខ្មែរ បងប្អូនខ្ញុំចេះនិយាយខ្មែរទាំងអស់ហ្នឹង ។

ដានីៈ តែគេនិយាយមកមីងគេនិយាយភាសាខ្មែរ?

អឿនៈ និយាយជនជាតិខ្ញុំលឺខ្ញុំតទៅមួយម៉ាត់ទៅ ។

ដានី៖ គាត់អត់ដែលមកលេងមីងទេ?

អឿន៖ អត់ អត់មកទេ អត់មកសោះ លុយគេមិនខ្វះទេ លុយកាក់គេ មានតែខ្ញុំទេអត់ ។

ដានី៖ មីងអត់អញ្ជើញគេមកលេង?

អឿន៖ ហៅគេមិនមក ។

ដានី៖ គេហៅមីងទៅវិញ?

អឿន៖ គេរវល់ធ្វើការរបស់របរចំការគេដែរ បើយើងរវល់តែដើរអីចឹងបានអី ដូចខ្ញុំអីចឹងខ្ញុំដើរទៅឆ្នាំនេះ ។

ដានី៖ មីងមកតាំងជំនាន់តស៊ូ មានសេសសល់ខោអាវ ស្បែកជើង មួក របស់របរកាលពីជំនាន់សង្គ្រាមមកមីងមាននៅសល់អត់?

អឿន៖ គ្មានទេ ប៉ុណ្ណឹងហើយ ។

ដានី៖ អត់មានសល់ខោអាវកាលពីជំនាន់ខ្មែរក្រហម?

អឿន៖ អត់ ។

ដានី៖ មួក ឆ្នាំង ចានកាលពីជំនាន់ចិនជួយ?

អឿន៖ អត់មានទេ គេមិនជួយទេឆ្នាំង ចាន គេជួយអង្ករ ជួយប្រហុក អំបិល ម្ហូបប៉ុណ្ណឹង ។

ដានី៖ ខោអាវស្លៀកពាក់?

អឿន៖ ខោអាវអស់ហើយឡើងប៉ុន្មានឆ្នាំហើយ ខោអាវគេ សៀវភៅចិនបាត់អស់ហើយ មិនដឹងទៅណាទៅណី ។

ដានី៖ ខ្ញុំអរគុណមីងច្រើនដែលបានផ្តល់បទសម្ភាសន៍ជាមួយខ្ញុំ អរគុណមីងច្រើន ។

**ចប់**